# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤៤៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- លិខិតលេខ ៦៧៨ សជណ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៦៩៦៨ កសក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១៖**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ១ ៤២៥,០៤៤៩ហិកតា (មួយពាន់ បួនរយម្ភៃប្រាំក្បៀសសូន្យពាន់បួនរយសែសិបប្រាំបួនហិកតា)ដែលមានទីតាំងស្ថិតនៅឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី របស់ក្រុមហ៊ុន កៅស៊ូ អេលែវ ប៊ីអិម យ៉ញស្តុក សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ០៨ប័ណ្ណ ហើយក្នុងប័ណ្ណនីមួយៗមានការចុះហត្ថលេខា និងត្រា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់គណៈអភិបាលខេត្តរតនគិរី។

www.pheakdeylaw.com

**មាត្រា២៖**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា៤
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com

## តំបន់សម្បទានដីតាំងដីស្នើសុំចុះបញ្ជីដីឯកជនរបស់រដ្ឋ
## ក្នុងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
ស្ថិតនៅឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី

| តារាងនិយាមកាចំណុចគោលព្រំ | | |
|---|---|---|
| Projection: UTM, Zone 48N; Datum WGS 84 | | |
| Point ID | Northing (m) | Easting (m) |
| A | 1495318.059 | 745502.822 |
| B | 1495310.131 | 748363.529 |
| C | 1494271.058 | 748485.221 |
| D | 1494116.510 | 749114.213 |
| E | 1498294.249 | 747212.610 |
| F | 1500346.824 | 748136.322 |
| G | 1500711.128 | 748617.230 |
| H | 1501221.306 | 745578.118 |
| I | 1497319.972 | 745572.313 |
| J | 1498841.076 | 739312.199 |
| K | 1499561.031 | 739864.177 |
| L | 1500420.715 | 740104.106 |
| M | 1500488.846 | 739252.742 |
| H | 1499746.766 | 738590.168 |
| O | 1500822.075 | 740256.766 |
| P | 1501345.766 | 740175.219 |
| Q | 1501416.503 | 738878.881 |
| R | 1498815.709 | 738627.442 |
| S | 1499951.538 | 737318.833 |
| T | 1499580.031 | 736642.151 |
| U | 1500820.309 | 735948.060 |
| V | 1501216.513 | 736903.097 |
| W | 1500682.149 | 735895.688 |
| X | 1499809.663 | 735824.708 |
| Y | 1498891.261 | 735979.092 |




សំគាល់
- ចំណុចព្រំ
- ព្រំក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- ដីស្នើសុំ ជាក្បាលដី ( ១៨២៥.០៤ ហ.ត )
- សហគមន៍ព្រៃឈើ ( ១៦៧០.៧៩ ហ.ត )
- ព្រៃរក្សាទុក ( ២៤៦.៤២ ហ.ត )
- តំបន់ទ្រនាប់អូរ ( ៧១២.០៨ ហ.ត )
- ដី ០១ ( ៣៩៥៤.៧១ ហ.ត )
- ព្រំប្រទល់រដ្ឋបាលស្រុក
- ព្រំប្រទល់រដ្ឋបាលឃុំ

0 1 2 km

បានឃើញ និងឯកភាព
រតនគិរី, ថ្ងៃទី...១៧... ខែ...តុលា....... ឆ្នាំ២០១៧
អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី

ថង សាវុន

រតនគិរី, ថ្ងៃទី...១៥... ខែ...តុលា....... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដីខេត្តរតនគិរី

ទឹម ស៊ីណាត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**

**និងសុរិយោដី ខេត្តរតនគិរី**

លេខ:...០២៦/០០៧.............

**សូមគោរពជូន**

**ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីលទ្ធផលក្រុមការងារចុះវាស់វែង និងសិក្សាផលប៉ះពាល់ក្នុងទីតាំងសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **កៅស៊ូ អេលៃរ ប៊ីអិម យ៉ាញស្ពុក** ។

**យោង** ÷ របាយការណ៍ស្តីពីការកំណត់ព្រំ និងវាស់វែងដី ដើម្បីចុះបញ្ជីដី នៃដីឯកជនរបស់រដ្ឋ ក្នុងដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន កៅស៊ូ អេលៃរ ប៊ីអិម យ៉ាញស្ពុក។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត** មេត្តាជ្រាបថា: អនុវត្តតាមលិខិតបង្គាប់ការរបស់សាលាខេត្តរតនគិរី ដោយមានការចូលរួមពីមន្ទីរ ស្ថាប័នពាក់ព័ន្ធ ក្រុមការងារដើរដ្ឋថ្នាក់ស្រុក អាជ្ញាធរដែនដី ប្រជាពលរដ្ឋ ក្រុមការងារបានចុះទៅដល់ទីតាំងសម្បទានដីសេដ្ឋកិច្ចជាក់ស្តែងចុចយកចំណុចនិយាមកា បង្គោលព្រំដីនិមួយៗ ពិនិត្យវាស់វែងផលប៉ះពាល់ដីស្រែ-ចំការ និងផលប៉ះពាល់ផ្សេងៗទៀត ដោយប្រើប្រាស់ឧបករណ៍ GPS Garmin 62s។

លទ្ធផលនៃការវាស់វែង មន្ទីរបានរៀបចំប្រជុំក្រុមការងារវាលដើម្បីពិនិត្យ ពិភាក្សា ដោយបានទទួលបានលទ្ធផលដូចខាងក្រោម ៖

| តារាងនិយាមកាចំណុចព្រំដីជាកម្មវត្ថុនៃ សម្បទានសេដ្ឋកិច្ច | | |
|---|---|---|
| ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី | | |
| Projection UTM, Zone 48N; Datum WGS 1984 | | |
| **Point ID** | **Northing (m)** | **Easting (m)** |
| A | 1495318.059 | 745502.822 |
| B | 1495310.131 | 748363.529 |
| C | 1494271.058 | 748485.221 |
| D | 1494116.510 | 749114.213 |
| E | 1498294.249 | 747212.610 |
| F | 1500346.824 | 748136.322 |
| G | 1500711.128 | 746617.230 |

www.pheakdeylaw.com

| | | |
|---|---|---|
| H | 1501221.306 | 745578.118 |
| I | 1497319.972 | 745572.313 |
| J | 1498841.076 | 739312.199 |
| K | 1499561.031 | 739864.177 |
| L | 1500420.715 | 740104.106 |
| M | 1500488.846 | 739252.742 |
| N | 1499746.766 | 738590.168 |
| O | 1500822.075 | 740256.766 |
| P | 1501345.766 | 740175.219 |
| Q | 1501416.503 | 738878.881 |
| R | 1498815.709 | 736627.442 |
| S | 1499551.538 | 737318.333 |
| T | 1499580.031 | 736642.151 |
| U | 1500820.309 | 736948.060 |
| V | 1501216.513 | 736503.097 |
| W | 1500662.149 | 735895.686 |
| X | 1499809.663 | 735624.708 |
| Y | 1498891.261 | 735979.052 |

ទំហំផ្ទៃដី នៃផលប៉ះពាល់ និងក្បាលដីស្នើសុំចុះបញ្ជីដី

| ប្រភេទដី | ទំហំ (ហិកតា) |
|---|---|
| តំបន់ព្រៃក្សាទុក | ២៨៦,៤២ |
| តំបន់ទ្រនាប់អូរ | ៨១២,០៨ |
| ដីប្រជាពលរដ្ឋតាមបទបញ្ជា០១ របស់រាជរដ្ឋាភិបាល | ៣៩៥៤,៨១ |
| ដីព្រៃសហគមន៍ | ១៦៨០,៧០ |
| ផ្ទៃដីដែលមិនបានដាំដុះ | ៤៤១០,៤០ |
| ផ្ទៃដីស្នើសុំចុះបញ្ជី | ១៤២៥,០៤ |

ដូច្នេះផ្ទៃដីឯកជនរបស់រដ្ឋ ដែលស្នើសុំចុះបញ្ជីដី ក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **កៅស៊ូ អេលៃរ ប៊ីអិម យ៉ាញស្តុក** មានចំនួន ០៨ ក្បាលដី ដែលមានទំហំសរុប **១៤២៥,០៤** ហិកតា។

អាស្រ័យដូចបានគោរពជំរាបជូនខាងលើ សូម **ឯកឧត្តមអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

រតនគិរី, ថ្ងៃទី..០៨....ខែ..ធ្នូ.....ឆ្នាំ២០១៧

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តរតនគិរី**

ង៉ិម ស៊ុនណារ៉េត

**បានឃើញ និងឯកភាព**

**អភិបាលខេត្ត និងជាប្រធានអង្គប្រជុំ**

**ថង សាវុន**